# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

គណបក្ស ហ៊្វុនស៊ិនប៉ិច

ជំរាបជូន

និពន្ធនាយក សារពត៌មាន មនសិការខ្មែរ

ការិយាល័យអ្នកនាំពាក្យគណបក្សហ៊្វុនស៊ិនប៉ិច សូមធ្វើការបដិសេធន៍ ទាត់ចោលទាំងស្រុង ចំពោះសារពត៌មាន មនសិការខ្មែរ ចេញផ្សាយឆ្នាំទី៩ លេខ ១៧៧៥ ថ្ងៃពុធ ខែតុលា ឆ្នាំ២០០២ ក្នុងអត្ថបទ មួយ ដែលមានចំណងជើងថា "ទ្រង់រណឫទ្ធិ ព្រមានដកសមាជិកសភាហ្វ៊ុនស៊ិនប៉ិចណា ដែលមិនចូលរួមប្រជុំ ប្រចាំប្រាំនៅថ្ងៃទី២៥ ខែតុលា" ។ លើឃ្លាមួយដែលសារពត៌មានបានចោទថា ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ បានព្រមានដល់សមាជិកសភា គណបក្សរាជានិយមហ៊្វុនស៊ិនប៉ិចថា នឹងដកចេញហើយលុបឈ្មោះចេញពីគណបក្សភ្លាម ប្រសិនបើអ្នកតំណាងរាស្ត្រទាំងនោះ មិនព្រមដង្ហែតាមព្រះអង្គចូលរួមប្រជុំរដ្ឋសភា ថ្ងៃទី២៥ តុលា.... វាជាការប្រាសចាកទាំងស្រុង ទៅនឹងការពិត ព្រោះថាសម្តេចព្រះប្រធាន មិនដែលបានធ្វើការព្រមាន ឬគំរាមកំហែងដល់ការដកចេញ ឬលប់ឈ្មោះចេញពីគណបក្សនូវសមាជិកសភាគណបក្សហ្វ៊ុនស៊ិនប៉ិចម្នាក់ណាឡើយ ព្រះអង្គគ្រាន់តែមាន ព្រះបន្ទូលថា " គណបក្សហ៊្វុនស៊ិនប៉ិចត្រូវតែយល់ ព្រោះនេះជាប្រវត្តិសាស្ត្រ ដែលខ្លួនដើរតួនាទីជាសមាជិក រដ្ឋសភា ដូច្នេះសមាជិកគណបក្សរាជានិយមហ៊្វុនស៊ិនប៉ិចត្រូវតែចូលរួមចំណែក " ។ ក្នុងព្រះបរមនាមសម្តេចក្រុមព្រះ ជាព្រះប្រធានរដ្ឋសភា ព្រះអង្គមានសិទ្ធិកោះអញ្ជើញសមាជិកសភាគ្រប់រូបឱ្យចូលរួមប្រជុំ ។ ចំណែកឯ សមាជិក សមាជិកាសភាគ្រប់រូបត្រូវតែបំពេញភារកិច្ចរបស់ខ្លួន គឺត្រូវចូលរួមប្រជុំ ហើយចំពោះអ្នកដែលមិនបានចូលរួមប្រជុំ គឺត្រូវបញ្ជាក់ពីមូលហេតុច្បាស់លាស់ ដូចដែលបានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា ។ សម្តេចព្រះប្រធាន ពុំដែលបានធ្វើការគាបសង្កត់ ឬបង្ខិតបង្ខំ សមាជិក សមាជិកានៃរដ្ឋសភាណាម្នាក់ឱ្យបោះឆ្នោតគាំទ្រនូវច្បាប់ណាមួយឡើយ ។ សមាជិកសភាគ្រប់រូបមាន សិទ្ធិគ្រប់គ្រាន់ក្នុងការបញ្ចេញមតិ ហើយបោះឆ្នោតតាមសតិសម្បជញ្ញៈរបស់ខ្លួន ។ ចំពោះករណីថា ដេញសមាជិកគណបក្សរាជានិយមហ៊្វុនស៊ិនប៉ិចដែលមិនចូលប្រជុំ សម្តេចព្រះប្រធានគ្រាន់តែ មានព្រះបន្ទូលរំលឹកដល់សមាជិក ដែលត្រូវឈរជាបេក្ខជនតំណាងរាស្ត្រឆ្នាំ២០០៣ប៉ុណ្ណោះ ព្រោះថាសមាជិក រដ្ឋសភាត្រូវតែជាអ្នកគ្រាឡាញ់មុខនាទីជាអ្នកតំណាងរាស្ត្រ--ដែលមានកិច្ចប្រជុំជាធំ ។

ដូច្នេះក្នុងព្រះឋានៈព្រះអង្គជាព្រះប្រធានគណបក្ស ព្រះអង្គនឹងពិនិត្យឡើងវិញនូវបេក្ខភាព អ្នកដែលនឹងឈរជាតំណាងរាស្ត្រសំរាប់អាណត្តិឆ្នាំ២០០៣ ខាងមុខ មិនមែនដកពីសមាជិកសភាបច្ចុប្បន្នទេ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែតុលា ឆ្នាំ២០០២

ការិយាល័យអ្នកនាំពាក្យគណបក្សហ៊្វុនស៊ិនប៉ិច

ចម្លងជូន

-ឯកឧត្តម ខៀវកាញារីទ្ធ រដ្ឋមន្ត្រីក្រសួងពត៌មាន

(ដើម្បីជ្រាបជាពត៌មានជូនខ្ពស់)